# I ទីស្តីការគណៈរដ្ឋមន្ត្រី

# អនុក្រឹត្យ

*រាជធានីភ្នំពេញចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៤*

**អនុក្រឹត្យលេខ ៣៨ អនក្រ**
**ស្តីពីការនិយ័តភាពជំពូកចំណាយ**
**រាជរដ្ឋាភិបាល**

-----

-បានឃើញរដ្ឋធម្មនុញ្ញ នៃ រាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ដោយ ព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ។

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា១: អនុញ្ញាតនិយ័តភាព ពីជំពូក ៥០ " ឥណទានសាងសង់ "ទៅជំពូក ៥១ " ឥណទានទទួលសំភារៈ " ជូនទៅរដ្ឋលេខាធិការដ្ឋាន ដូចខាងក្រោម :

- រដ្ឋលេខាធិការដ្ឋានកិច្ចការនារី : ១៦០.០០០.០០០៛
- រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា : ២០.០០០.០០០៛

មាត្រា២: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវទទួលអនុវត្តន៍អនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៤

**អនុក្រឹត្យលេខ ៣៩ អនក្រ**

**ស្តីពី**

**ការលុបចោល អនុក្រឹត្យលេខ ១១ អ.ន.ក្រ**

**ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពី**

**ការបង្កើតគណៈកម្មការចំរុះ បង្ការបង្ក្រាប**

**សកម្មភាព លួច ឆក់ ប្លន់ ប្រដាប់អាវុធ**

**រាជរដ្ឋាភិបាល**

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា